សូមស្វាគមន៍ចូលមក វិបស័យ (website) របស់ក្រុមហ៊ុនច្បាប់យើង Weinstein, Schleifer & Kupersmith, P.C. ដែលជាក្រុមមេធាវី ខាងការកាត់សេចក្តី ខូះខ្នែងធ្វើការ មានសម្ថកិច្ច ហើយមានមេត្តាធម៌ និងមានឯកទេសកម្មខាង របួស ទារប្រាក់ពីកន្លែងធ្វើការពេលឈឺឬមានរបួសនៅកន្លែងធ្វើការ (workers' compensation) និង ប្រាក់ពិការ (social security disability) នៅរដ្ឋផិនស៊ីលវេញ៉ា និង ញូជ័រស៊ី ។ មេធាវី អ្នកធ្វើការឲ្យមេធាវី និងបុគ្គលិកដែលមានការពិសោធន៍របស់យើងមានការយកចិត្តទុកដាក់ដល់លោកអ្នកយ៉ាងខ្លាំង ។ អស់រយៈពេលជាង៥០ឆ្នាំកន្លងមកនេះ យើងបានប្តឹងទាមទារប្រាក់ពីក្រុមហ៊ុនធំៗ និងពីក្រុមហ៊ុនធានារ៉ាប់រង ... ហើយយើងឈ្នះ ។ យើងមានការប្រឹងប្រែង មានការចេះដឹង ហើយមានការស៊ូប្តូរចំពោះអ្វីៗដើម្បីជួយអតិថិជនរបស់យើង ទោះជាមានរបួសស្រាល ឬធ្វើឲ្យពិការរហូតក៏ដោយ ។ យើងមានមោទនភាពលើការណែនាំអតិថិជនរបស់យើង ឲ្យឆ្លងកាត់នូវភាពលំបាកនិងភាពច្របូកច្របល់ ដែលកើតមានឡើងក្រោយពេលមានរបួស ។ យើងជួយមនុស្សម្នាក់ៗឲ្យបាននូវអត្ថប្រយោជន៍ដែលត្រូវតាមការត្រូវការរបស់គេ ពីអង្គការដែលមិនយកកម្រៃផ្សេងៗ និងពីរដ្ឋាភិបាល ។ យើងមានការចេះដឹងអំពីច្បាប់ ប្រព័ន្ធតុលាការ និងក្រុមហ៊ុនធានារ៉ាប់រង ហើយយើងមានឈ្មោះល្បីល្បាញក្នុងសហគមន៍ និងក្នុងចំណោមមេធាវីនានា ចំពោះអ្វីៗដែលយើងធ្វើ និងមេត្តាធម៌ដែលយើងមានមកលើអតិថិជនរបស់យើង ។ យើងមានមោទនភាពក្នុងការជួយដល់សហគមន៍ ដោយធានាឲ្យមានការអប់រំតាមការពិភាក្សាគ្នាជាក្រុម និងតាមការបង្រៀនខ្លីៗ ហើយដោយសហការណ៍ជាមួយអ្នកដឹកនាំនៅ មជ្ឈមណ្ឌលនានាក្នុងសហគមន៍ អង្គការផ្នែកខាងសាសនា និងជំនួញផ្សេងៗ ។

ពេលជួបជាមួយមេធាវីរបស់យើងដើម្បីពិភាក្សារឿងរបស់លោកអ្នក យើងមិនយកថ្លៃជួបទេ ហើយយើងក៏មិនយកថ្លៃអ្វីទាំងអស់ លើកលែងតែមេធាវីរបស់យើងប្តឹងបានប្រាក់សម្រាប់លោកអ្នក ។ យើងមានបុគ្គលិកដែលចេះនិយាយភាសា អេស្ប៉ាញ៉ុល (Spanish) រុស្ស៊ី (Russian) និង អ៊ីតាលី (Italian) យ៉ាងច្បាស់លាស់ ដែលអាចជួបជាមួយលោកអ្នកនៅការិយាល័យណាមួយក្នុងចំណោមការិយាល័យទាំងប្រាំមួយរបស់យើង ដែលស្ថិតនៅ Philadelphia, Reading, Lancaster, Avondale, Lebanon, និង Allentown, Pennsylvania ។ យើងក៏មានមេធាវីដែលមានសិទ្ធិធ្វើការនៅរដ្ឋ New Jersey ។ បើលោកអ្នកមិនអាចធ្វើដំណើរមកកាន់ការិយាល័យណាមួយរបស់យើងបាន មេធាវីរបស់យើងសុខចិត្តទៅជួបលោកអ្នកនៅផ្ទះរបស់លោកអ្នក ។ យើងសន្យាធ្វើជាតំណាងដែលមានប្រសិទ្ធិភាពជាទីបំផុត និងជាតំណាងច្បាប់ដែលធ្វើឲ្យបានរហ័ស ។

ក្រុមមេធាវីរបស់យើង និងអ្នកធ្វើការអោយមេធាវីទាំងអស់នឹងធ្វើអ្វីៗទាំងអស់ជូនលោកអ្នក ដើម្បីឲ្យបានសំណងនិងថ្លៃធានារ៉ាប់រង អត្ថប្រយោជន៍ពីកន្លែងធ្វើការ និងពីរដ្ឋាភិបាល ដែលលោកអ្នកមានសិទ្ធិទទួល ។ យើងនឹងយកសេចក្តីរាយការណ៍នៃឧប្បត្តិហេតុនិងសេចក្តីរាយការណ៏របស់ប៉ូលីស សំណុំរឿងពេទ្យ សេចក្តីថ្លែងរបស់សាក្សី និងពត៌មានពីកន្លែងរធ្វើការ ។ យើងនឹងជួយលោកអ្នកអោយទទួលការព្យាបាលតាមការត្រូវការ ហើយអោយគេសងថ្លៃសំណងអោយ ។ យើងតែងតែទូរស័ព្ទត្រឡប់ទៅលោកអ្នកវិញយ៉ាងរហ័ស ហើយផ្តល់ដំណឹងថ្មីៗលើស្ថានការណ៏នៃសំណុំរឿងរបស់លោកអ្នក ។

ក្រសួងផ្នែកខាងជួយអ្នកដែលមានរបួសនៅ Weinstein, Schleifer & Kupersmith, P.C. តំណាងអោយ ហើយជួយអ្នកដែលមានរបួសដោយសាកាលៈទេសៈណាមួយដូចតទៅនេះៈ

- គ្រោះថ្នាក់ម៉ូតូ
- ផ្ទះសម្បែងដែលមានលក្ខណៈនាំឲ្យមានគ្រោះថ្នាក់
- របស់របរដែលបណ្តាលឲ្យមានគ្រោះថ្នាក់
- ការព្យាបាលដោយធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់
- ការមិនយកចិត្តទុកដាក់នៅមណ្ឌលមើលថែមនុស្សចាស់និងអ្នកពិការ
- គ្រោះថ្នាក់សំណង់
- ស្លាប់ដោយការធ្វើមកលើខុសច្បាប់
- បារណាដែលនៅតែលក់ស្រាឲ្យអ្នកដែលកំពុងស្រវឹង ដែលនាំឲ្យមានគ្រោះថ្នាក់
- ការធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់ទូទៅ

បន្ថែមពីលើនេះទៀត យើងក៏ធ្វើបណ្តឹងដើម្បីទារប្រាក់ពីក្រុមហ៊ុនធានារ៉ាប់រងណាដែលមិនស្មោះត្រង់ ។

ការិយាល័យមេធាវី Weinstein, Schleifer & Kupersmith, P.C. ក៏មានក្រសួងផ្នែកខាងជួយទារប្រាក់ពេលឈឺឬមានរបួសនៅកន្លែងធ្វើការ ដែលមិនអាចធ្វើការបានតទៅទៀត ។ តាមច្បាប់នៅរដ្ឋផិនស៊ីលវេញ៉ា អ្នកដែលមានរបួសនៅកន្លែងធ្វើការមានសិទ្ធិទទួលប្រាក់នៅពេលមិនអាចធ្វើការបាន ។ កន្លែងធ្វើការរបស់អ្នកដែលមានរបួស និងក្រុមហ៊ុនធានារ៉ាប់រងខាងសងប្រាក់នៅពេលមិនអាចធ្វើការបាន ក៏ត្រូវទទួលខុសត្រូវក្នុងការចេញថ្លៃព្យាបាលដែលទាក់ទងទៅនឹងរបួសនៅកន្លែងធ្វើការណាដែលចាំបាច់ត្រូវព្យាបាលដែរ ។

ទោះជាកន្លែងធ្វើការនិងក្រុមហ៊ុនធានារ៉ាប់រងរបស់ពួកគេត្រូវទទួលខុសត្រូវក្នុងការអោយប្រាក់ និងចេញថ្លៃព្យាបាលអោយនៅពេលមានរបួសក៏ដោយ ជាទូទៅ វាជាការចាំបាច់ត្រូវរកជំនួយពីមេធាវីដើម្បីទទួលអត្ថប្រយោជន៍ទាំងនេះ ។ ក្រុមមេធាវីរបស់យើង និងអ្នកធ្វើការអោយមេធាវី រីករាយនឹងជួបលោកអ្នកដើម្បីពន្យល់ពីសិទ្ធិនិងកាតព្វកិច្ចរបស់លោកអ្នក ។ បើចាំបាច់ យើងនឹងដាក់បណ្តឹងឲ្យត្រូវតាមសេចក្តីត្រូវការ ដើម្បីធ្វើឲ្យច្បាស់ថាលោកអ្នកនឹងទទួលប្រាក់ដែលលោកអ្នកមានសិទ្ធិទទួល ។ យើងនឹងជួយលោកអ្នកឲ្យទទួលការព្យាបាល ហើយនឹងមើលឲ្យច្បាស់ថាថ្លៃព្យាបាលរបស់លោកនឹងត្រូវចេញថ្លៃអោយ ។

ជាចុងក្រោយបង្អស់ ក្រសួងផ្នែកខាងសុំប្រាក់ពិការនឹងផ្តល់ជំនួយក្នុងការជួយឲ្យបានអត្ថប្រយោជន៍ពិការ ពីក្រសួង សូស្យល់សិខ្យូរីធី (Social Security Administration) ។ បុគ្គលិកដែលមានការពិសោធន៍នឹងណែនាំអ្នកទាំងឡាយណា ដែមិនអាចធ្វើការបាន ដោយសាមានជម្ងឺឬមានរបួស តាមប្រព័ន្ធរដ្ឋាភិបាលអោយទទួលប្រាក់និងសំបុត្រពេទ្យផ្សេងៗ ។

**WSK - យើងផ្តល់កិត្តិយសដល់ការប្រឹងប្រែងធ្វើការនិងការងារដែលមានគុណភាព គ្រប់ចំណុចនៃការអនុវត្តន៍របស់យើង ។**